00818179



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 06 / 2012
ម៉ោង (Time/Heure): 16:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

**សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន

00818180



Jacques VERGÈS
Arthur VERCKEN
Anta GUISSÉ

# I សេចក្តីផ្តើម

១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសេចក្តីសន្និដ្ឋាន អនុលោមតាមវិធាន ៩២ ដែលសហព្រះរាជ-អាជ្ញាបានដាក់ កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។ សហព្រះរាជអាជ្ញាបានជំទាស់ថា មិនមានសិទ្ធិដាច់ខាតណាមួយ ដើម្បីកោះហៅ និងសាកសួរសាក្សីទាំងអស់ ដែលកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងអស់នោះ ត្រូវបានស្នើសុំឱ្យដាក់បញ្ចូលជាភស្តុតាងនោះទេ។ សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យអង្គជំនុំជម្រះ ទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន ដោយមិនបាច់កោះហៅសាក្សីឱ្យចូលមកបង្ហាញខ្លួន នៅពេលសវនាការនោះទេ។ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះយកគោលការណ៍ណែនាំពីវិធាននានា ដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះ ផ្អែកតាមស្ថានភាពមួយចំនួន ទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដាក់បញ្ចូលជាភស្តុតាង ដោយមិនចាំបាច់តម្រូវឱ្យសាក្សីទាំងនេះ បង្ហាញខ្លួនសម្រាប់ការសួរដេញពីភាគីនោះឡើយ[1]។

២ ទាក់ទងនឹងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវកោះហៅឱ្យចូលបង្ហាញខ្លួននៅពេលសវនាការ អង្គជំនុំជម្រះបានបង្ហាញពីមុនថា កំណត់ហេតុស្តាប់ចម្លើយពីមុនៗទាំងអស់ អាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយភាគីនានាមានឱកាសសួរដេញដោលបុគ្គលទាំងនេះ ស្តីពីចំណុចខុសគ្នាពាក់ព័ន្ធផ្សេងៗដែលត្រូវបានចោទប្រកាន់ រវាងកំណត់ហេតុជាខ្សែអាត់សំឡេង និងកំណត់ហេតុស្តាប់ចម្លើយជាសំណេរពីមុន នៅពេលដែលបុគ្គលទាំងនោះត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ[2]។

៣ សេចក្តីសម្រេចនេះ ពាក់ព័ន្ធតែជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលនានា ដែលមិនត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ ប៉ុន្តែភស្តុតាងរបស់បុគ្គលទាំងនោះ ត្រូវបានភាគីមួយស្នើសុំឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយជាលាយ

---

[1] "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E96 ("សំណើរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ២, ៣១, ៣៥ និង៤១។

[2] សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E142/3 ("សេចក្តីសម្រេចទាក់ទងនឹងកំណត់ហេតុជាសំឡេង") កថាខណ្ឌ១៣។

លក្ខណ៍អក្សរ ឬប្រតិចារឹក ដោយរួមបញ្ចូលនូវបណ្ដឹងចំនួន ៤១២៩ និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣៨៦៦ ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កំណត់ហេតុស្ដាប់ចម្លើយនានា ដែលត្រូវបានប្រមូលដោយអង្គភាពនានានៅក្រៅអ.វ.ត.ក និងប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូងចំនួន ៦៩ ក្នុងសំណុំរឿង ០០១ ដែលត្រូវបានភាគីមួយ ឬច្រើនស្នើសុំឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ[3]។

## II. ប្រវត្តិនីតិវិធី

៤ កាលពីថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ ដែលបង្ហាញថា សហព្រះរាជអាជ្ញាបានដកចេញនូវបុគ្គលមួយចំនួនពីក្នុងបញ្ជីទាំងនេះ ដោយផ្អែកលើមូលដ្ឋានថា កំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់បុគ្គលទាំងនោះ និងឯកសារពាក់ព័ន្ធនានា ត្រូវបានអនុញ្ញាតឲ្យដាក់

[3] "បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន ៨០(៣)" ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/31, កថាខណ្ឌ ១៩, ២១; *សូមមើលផងដែរ* "ឧបសម្ព័ន្ធ ១១៖ កំណត់ហេតុជាលាយលក្ខណ៍អក្សរពេលជំនុំជម្រះនៃសំណុំរឿង ០០១" ឯកសារ E9/31.11 (ដែលមានប្រតិចារឹក ពេលសវនាការក្នុងសំណុំរឿង ០០១ ក្នុងនោះមានសក្ខីកម្មរបស់ ឌុច និង សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ដែលទាក់ទិននឹងមន្ទីរ ស២១ និងរបបកម្ពុជាប្រជាធិបតេយ្យ); "ឧបសម្ព័ន្ធ ១៣៖ ពាក្យបណ្ដឹង" ឯកសារ E9/31.13 (ដែលមានបណ្ដឹងចំនួន ៤១៤); "បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ឧបសម្ព័ន្ធ ៧ និង ៨)" ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/32, កថាខណ្ឌ ១៣ (ដែលមានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣.៩៨១ រួមទាំងពាក្យសុំដែលសហចៅក្រមស៊ើបអង្កេតបានច្រានចោល ហើយត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ បន្ថែមទៅលើបណ្ដឹងចំនួន ៤.១២៩); "ឧបសម្ព័ន្ធ ៧(ក)(i)៖ សំណើសម្រាប់ឯកសារជាក់លាក់នៅក្នុងសំណុំរឿង ដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី" ឯកសារ E9/32.2; "បញ្ជីឯកសារ និងវត្ថុកែប្រែរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសវនាការដំណាក់កាលបួនដំបូង" ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E109/2, កថាខណ្ឌ ១២ និង "ឯកសារបន្ថែម ២៖ ឧបសម្ព័ន្ធ ៧(ក)(iii)៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ឯកសារ E109/2 (ដែលបង្ហាញថា ចំនួនពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះមានចំនួន ៣.៨៦៦)។ បញ្ជីរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខក៏មានសេចក្ដីថ្លែងការណ៍របស់បុគ្គលរាប់រយ ដែលអង្គការនានាបានប្រមូលយកដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។ ពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍ ដែលបានប្រមូលដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ក្នុងពេលស៊ើបអង្កេត *សូមមើល* "សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង ០០២/០១" ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E185 ("សេចក្ដីសម្រេចលើឯកសារដែលបានស្នើសុំ") កថាខណ្ឌ ២០។

បញ្ចូលជាភស្តុតាង អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាបានរក្សាសិទ្ធិក្នុងការកោះហៅបុគ្គលផ្សេងៗបន្ថែមទៀត ប្រសិនបើការសម្រេចរបស់អង្គជំនុំជម្រះមិនទទួលយកចម្លើយរបស់សាក្សីនានានិងឯកសារពាក់ព័ន្ធផ្សេងៗ ធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពក្នុងការបង្ហាញនូវភស្តុតាងដាក់បន្ទុកចំពោះបញ្ហាជាក់លាក់ណាមួយ[4]។

៥ ជនជាប់ចោទទាំងអស់ បានឆ្លើយតបថា មេធាវីការពារក្តីមានសិទ្ធិតទល់ជាមួយនឹងសាក្សីទាំងអស់ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួន និងដែលមេធាវីការពារក្តីមិនមានឱកាសតទល់ក្នុងអំឡុងពេលកិច្ចស៊ើបអង្កេត ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយទាំងនោះត្រូវបានបញ្ចូលជាភស្តុតាងនៅពេលបន្ទាប់មក[5]។ មេធាវីការពារក្តី បានយោងលើអនុស្សរណៈដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើឱ្យក្រុមមេធាវីការពារក្តីទាំងអស់ កាលពីខែមករា ឆ្នាំ២០០៨ ដែលបង្ហាញថា មិនមានសិទ្ធិដាច់ខាតណាមួយ ដើម្បីធ្វើការតទល់នៅដំណាក់កាលស៊ើបអង្កេត និង "ដោយមូលហេតុនេះហើយ វិធាន ៨៤(១) ទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងដំណាក់កាលជំនុំជម្រះ ក្នុងការតទល់សាក្សីដាក់បន្ទុក ដែលជនត្រូវចោទមិនទាន់បានតទល់នៅដំណាក់កាលស៊ើបអង្កេត"[6]។

៦ កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានបង្ហាញថា សហព្រះរាជអាជ្ញាមានបំណងដាក់ឯកសារមួយចំនួនជូនដល់អង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងដោយឯកសារទាំងអស់នោះរួមបញ្ចូលទាំងចម្លើយសាក្សីចំនួន១៤១៥ (រួមមានកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន៨៨២ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងចម្លើយ

---

[4] "បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញារួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៤ និងទី៥" ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9/4 ("បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ១០។

[5] "ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០" ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/1 កថាខណ្ឌ ២; "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង" របស់ នួន ជា ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/4 កថាខណ្ឌ ៨; "បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ" របស់ ខៀវ សំផន ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/6 កថាខណ្ឌ ១១; "សេចក្តីបញ្ជាក់របស់អ្នកស្រី អៀង ធីរិទ្ធ អំពីចេតនាជំទាស់ទៅនឹងសាក្សី និងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និង នួន ជា" ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E9/4/11 កថាខណ្ឌ ៤, ៦, ២៦; *សូមមើលផងដែរ* "សំណើរបស់អ្នកស្រី អៀង ធីរិទ្ធ សុំដាក់បញ្ជីឯកសាររបស់ខ្លួន" ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៦។

[6] "ការឆ្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ធ្នូ ២០០៧ ស្តីពីកិច្ចស៊ើបអង្កេត" ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ឯកសារ A110/I ទំព័រទី២។

សាក្សីផ្សេងៗ ព្រមទាំងឧបសម្ព័ន្ធដែលប្រមូលបានដោយអង្គភាពផ្សេងៗ ដែលមិនជាប់ទាក់ទងនឹងកិច្ចស៊ើបអង្កេត) បណ្ដឹងចំនួន៤១៤ ព្រមទាំងប្រតិចារឹកពីសំណុំរឿង ០០១ ចំនួន៦៩[7]។ នៅថ្ងៃដដែលនោះដែរ សហមេធាវីនាំមុខ បានបង្ហាញថា ខ្លួនមានចេតនាដាក់ចំពោះមុខអង្គជំនុំជម្រះនូវបណ្ដឹងចំនួន៤១២៩ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣៩៨១ នៅក្នុងសំណុំរឿង ០០២ទាំងអស់ (ពោលគឺ មិនមែនត្រឹមតែដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ចំនួន៣៨៦៦ ដែលត្រូវបានទទួលស្គាល់ជាចុងក្រោយក្នុងសំណុំរឿង០០២នោះទេ) និងកំណត់ហេតុស្ដាប់ចម្លើយសាក្សីជាច្រើនទៀត[8]។

៧ សហព្រះរាជអាជ្ញាបានដាក់សំណើសុំរបស់ខ្លួន នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១[9]។ ក្រុមមេធាវីការពារក្ដីទាំងអស់ជំទាស់នឹងសំណើនេះ[10]។

---

[7] "បញ្ជីឯកសារ របស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន ៨០(៣)" ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/31 កថាខណ្ឌ ១, ១៩-២១ (កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដែលផ្ដល់ដោយសហព្រះរាជអាជ្ញាមានចំនួនខុសគ្នា ដោយសារមានបញ្ចូលឯកសារដទៃទៀតដូចជា ឧបសម្ព័ន្ធដែលភ្ជាប់ជាមួយនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនោះផង); "ឧបសម្ព័ន្ធ ១៣៖ ពាក្យបណ្ដឹង" ឯកសារ E9/31.13; "ឧបសម្ព័ន្ធ ១១៖ កំណត់ហេតុជាលាយលក្ខណ៍អក្សរពេលជំនុំជម្រះនៃសំណុំរឿង ០០១" ឯកសារ E9/31.11។

[8] "បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ឧបសម្ព័ន្ធ ៧ និង ៨)" ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/32 កថាខណ្ឌ ១៣; "ឧបសម្ព័ន្ធ ៧(ក)(i)៖ បញ្ជីឯកសារ និងវត្ថុតាង៖ សំណើសម្រាប់ឯកសារដាក់លាក់នៅក្នុងសំណុំរឿងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី" ឯកសារ E9/32.2។

[9] "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E96 ("សំណើរបស់សហព្រះរាជអាជ្ញា")។

[10] "សារណាឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី" ឯកសារ E96/1 ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ នួន ជា"); "ចម្លើយតបរបស់ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ ទៅនឹង "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ឯកសារ E96/2 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង ធីរិទ្ធ"); "ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ឯកសារ E96/3 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ អៀង សារី") និង "សេចក្ដីសង្កេតតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី" ឯកសារ E96/4, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ ខៀវ សំផន"); *សូមមើលផងដែរ* "សេចក្ដីជំទាស់មិនទទួលយកបញ្ជីឯកសារដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង" (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) របស់ ខៀវ សំផន ឯកសារ E131/6 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ២២-២៣; "ការជំទាស់របស់លោក អៀង សារី ទៅ

## III. សារណា

៨ ថ្វីបើមានការប្រើពាក្យក្នុងសំណៅជាភាសាអង់គ្លេសក្នុងវិធាន ៨៤(១) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សហព្រះរាជអាជ្ញាលើកឡើងថា សិទ្ធិរបស់ជនជាប់ចោទ ដើម្បីកោះហៅសាក្សីទាំងអស់ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងជនជាប់ចោទ មិនមែនជាសិទ្ធិដាច់ខាតនោះទេ។ នៅពេលបកស្រាយដោយពិចារណាទៅលើបទដ្ឋានអន្តរជាតិ ពាក្យពេចន៍ "ដាក់បន្ទុក" នៅក្នុងវិធាន ៨៤(១) ក្នុងសំណៅជាភាសាអង់គ្លេស និងភាសាខ្មែរ បានផ្តល់សិទ្ធិឱ្យជនជាប់ចោទ តទល់នឹងសាក្សី ដែលផ្តល់សក្ខីកម្មលើអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬចំណុចសំខាន់ផ្សេងទៀត នៃសំណុំរឿង[11]។ ជាទូទៅ ផ្អែកតាមការអនុវត្តរបស់តុលាការផ្សេងទៀតដែលកាត់សេចក្តីលើសំណុំរឿងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ អង្គជំនុំជម្រះសាលាដំបូងអាចអនុវត្តវិធីសាស្ត្រដែលអាចបត់បែនបាន ក្នុងការទទួលយកភ័ស្តុតាង ដើម្បីធានាឱ្យដំណើរការនីតិវិធីមានភាពឆាប់រហ័ស។ ដោយយោងលើតួនាទីចម្បងរបស់អង្គជំនុំជម្រះក្នុងការធានាឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទទួលយកប្រភេទនៃកំណត់ហេតុស្តាប់ចម្លើយមួយចំនួន ដោយមិនចាំបាច់កោះហៅសាក្សី ដើម្បីមកផ្តល់សក្ខីកម្មនៅសវនាការនោះទេ[12]។

៩ សហព្រះរាជអាជ្ញាលើកឡើងថា យុត្តិសាស្ត្ររបស់តុលាការ ICTY បានឆ្លុះបញ្ចាំងអំពីវិធាននានាដែលបង្កើតឡើង នៅកម្រិតអន្តរជាតិ ដោយអនុញ្ញាតឱ្យអង្គជំនុំជម្រះទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលពាក់ព័ន្ធនឹងភ័ស្តុតាងអំពីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ប៉ុន្តែមិនមែន

---

នឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន" ឯកសារ E114 ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២០ និង "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន"" ឯកសារ E114/1 ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៥០-៥១។

[11] "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានាទាក់ទងនឹងការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E96/6 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ៧។

[12] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤ និង ៤០; *សូមមើលផងដែរ* "ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E96/5 ("ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ៧, ១០-១១, ១៦-១៧, ២១; ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥-៦; *សូមមើលផងដែរ* វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង (ដែលថ្លែងជាគោលការណ៍ទូទៅមួយថា រាល់ភ័ស្តុតាងទាំងអស់អាចទទួលយកបាន)។

សក្ខីកម្មដែលបង្ហាញភស្តុតាងអំពីអំពើ ឬអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ (លុះត្រាណាសាក្សីទទួលមរណភាព ឬសាក្សីមិនអាចរកឃើញ ឬសាក្សីមិនអាចផ្តល់សក្ខីកម្មបាន)[13]។ ក្នុងការវាយតម្លៃរបស់ខ្លួន អង្គជំនុំជម្រះគួរតែពិចារណាអំពីវិសាលភាព ដែលភស្តុតាងអាចបង្ហាញពីអំពើ ឬអាកប្បកិរិយារបស់ជនជាប់ចោទ វិសាលភាពនៃភស្តុតាងដែលអាចបញ្ជាក់ទៅលើភស្តុតាងផ្ទាល់មាត់ ភាពជឿទុកចិត្តបាន និងតម្លៃជាភស្តុតាង។ អង្គជំនុំជម្រះក៏ត្រូវពិចារណាផងដែរពីភាពអាចមានសាក្សីដែលត្រូវមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងផលប៉ះពាល់នៃសវនាការស្តាប់សាក្សីដែលបានផ្តល់ចម្លើយក្នុងកំណត់ហេតុនីមួយៗ និងទៅលើរយៈពេលរួមរបស់សវនាការ[14]។ យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ក៏បានអនុញ្ញាតឱ្យមានការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ដែលទទួលបានក្នុងអំឡុង ពេលកិច្ចស៊ើបអង្កេតសម្រាប់ធ្វើជាភស្តុតាងបាន នៅពេលដែលជនជាប់ចោទមានឱកាសគ្រប់គ្រាន់ និងត្រឹមត្រូវ ដើម្បីតទល់នឹងភស្តុតាងប្រឆាំងលើរូបគាត់ និងនៅពេលដែលកំណត់ហេតុជាលាយ លក្ខណ៍អក្សរនោះ មិនមែនជាមូលដ្ឋានតែមួយគត់ សម្រាប់ផ្តន្ទាទោស[15]។

១០ សហព្រះរាជអាជ្ញាសង្កត់ធ្ងន់ថា កំណត់ហេតុស្តាប់ចម្លើយជាច្រើន ដោយផ្អែកតាមសេចក្តីសង្ខេបឯកសារ និងសាក្សី អនុលោមតាមវិធាន ៨០ គួរតែត្រូវបានទទួលយក ដោយសារតែកំណត់ហេតុទាំងនោះ មិនពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬអ្នកឋិតក្រោមបង្គាប់ផ្ទាល់របស់ពួកគាត់នោះទេ ប៉ុន្តែកំណត់ហេតុស្តាប់ចម្លើយទាំងនោះពាក់ព័ន្ធនឹងភស្តុតាងអំពីទីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ផលប៉ះពាល់នៃឧក្រិដ្ឋកម្មលើជនរងគ្រោះ និងបញ្ហាផ្សេងទៀត ដូចជា

---

[13] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២-២៣ (ដែលបានវិភាគពីទម្លាប់អនុវត្តន៍របស់តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") ពីការទទួលយកចម្លើយសាក្សី និងប្រតិចារឹកពីតុលាការដទៃទៀត); *សូមមើលផងដែរ* ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២០-២១ (ដោយកត់សម្គាល់នូវវិធាននីតិវិធី និងយុត្តិសាស្ត្រជាសារវ័ន្តដែលស្រដៀងគ្នារបស់តុលាការឧក្រិដ្ឋអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR") តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") និងតុលាការពិសេសសម្រាប់ប្រទេសលីបង់) និង ២២-២៧ (ដែលកត់សម្គាល់ថា ដូចដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានបកស្រាយគឺថា លក្ខន្តិកៈទីក្រុងរ៉ូមបានផ្តល់អំណាចឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីទទួលយកជាភស្តុតាងដោយពុំតម្រូវឱ្យសាក្សីបង្ហាញខ្លួនទេ ដោយផ្អែកលើភាពពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងរបស់វាដែលមានសារៈសំខាន់ជាងផលប៉ះពាល់របស់វា)។

[14] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៥, ៣៣។

[15] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧, ៩-១០; *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២-៣៣។

គោលនយោបាយ វចនាសម្ព័ន្ធទំនាក់ទំនង និងអត្ថិភាពនៃផែនការឧក្រិដ្ឋរួម។ ហេតុដូច្នេះ កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ត្រូវតែទទួលយក ដោយមិនចាំបាច់កោះហៅសាក្សីឱ្យមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការនោះទេ ដើម្បីជួយសម្រួលដល់សវនាការឱ្យប្រព្រឹត្តទៅមានភាពយុត្តិធម៌ និងបញ្ចប់ក្នុងរយៈពេលមួយសមស្រប[16]។

១១ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា អង្គជំនុំជម្រះគួរតែស្វែងរកការណែនាំពីវិធាននានាដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ និងច្នៃប្រឌិតបន្ថែមលើវិធានទាំងនេះ ដើម្បីឱ្យក្លាយជានីតិវិធីដែលអាចអនុវត្តបាននៅ អ.វ.ត.ក។ ដោយសារតែកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានធ្វើឡើងដោយមានសម្បថ បានកត់ត្រាដោយមន្ត្រីតុលាការ បានចុះហត្ថលេខាដោយសាក្សី និងអមមកជាមួយនឹងខ្សែអាត់សំឡេង ដូចនេះកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មានសញ្ញាបង្ហាញអំពីភាពជឿទុកចិត្តបានច្បាស់លាស់ និងមានតម្លៃជាភ័ស្តុតាង។ ការពិចារណាដូចគ្នានេះ ក៏បានអនុវត្តលើប្រតិចារឹកក្នុងសំណុំរឿង ០០១ ឬកំណត់ហេតុស្តាប់ចម្លើយពីមុនៗ ដែលបានអានជូនសាក្សីក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និងដែលសាក្សីបានស្បថថាពិត[17]។

១២ ចំពោះប្រភេទនៃកំណត់ហេតុស្តាប់ចម្លើយ ឬឯកសារផ្សេងៗទៀត ដែលប្រមូលបាន តាំងពីមុនកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាលើកឡើងថា នីតិវិធីដែលប្រើប្រាស់នៅតុលាការអន្តរជាតិនានា បានផ្តល់នូវវិធីសាស្ត្រជាជម្រើសផ្សេងៗក្នុងការបង្កើតឱ្យមានភាពជឿទុកចិត្ត (ដូចជាតាមរយៈការបញ្ជាក់ដោយអ្នកផ្តល់ចម្លើយ ដែលអត្ថន័យនៃចម្លើយនោះ គឺពិត និងត្រឹមត្រូវ ដូចមានចែងនៅក្នុងអនុវិធាន ៩២*ស្ទួន* (ខ) នៃវិធាននីតិវិធីនិងភ័ស្តុតាងរបស់តុលាការ ICTY)។ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះអាចប្រើប្រាស់វិធីសាស្ត្រស្រដៀងគ្នានេះ តាមរយៈការស្វែងរកការបញ្ជាក់ពីអ្នកស្រាវជ្រាវអំពីកាលៈទេសៈនៃការយកកំណត់ហេតុ ឬក៏ស្នើសុំឱ្យដាក់ភ័ស្តុតាងបន្ថែមអំពីភាពជឿទុកចិត្តបាន ដូចជាកំណត់ត្រា និងខ្សែអាត់សំឡេងក្នុងពេលដំណាលគ្នា។ ជាចុងក្រោយ សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់សាក្សី

---

[16] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២(ឃ) និង ៣៦ (ដោយបានផ្តល់យោបល់បន្ថែមទៀតថា អង្គជំនុំជម្រះគួរតែវាយតម្លៃទៅលើចម្លើយនានាជាដំណាក់កាលៗ ទៅតាមដំណើរការនៃនីតិវិធី និងវិធានទៅតាមតម្រូវការនៃការកោះហៅសាក្សីឱ្យបានមុនក្នុងដំណាក់កាលនីមួយៗនៃសវនាការ)។

[17] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨។

ដែលទទួលមរណភាព ឬមិនអាចរកឃើញដោយការព្យាយាមសមហេតុផល ដូចមានចែងក្នុងវិធាន៩២*ស្ទួន៤*នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY[18]។

១៣ ដើម្បីគាំទ្រដល់សំណើសុំរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមថា សិទ្ធិក្នុងការតទល់នឹងសាក្សី ដែលមានចែងនៅក្នុងមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានកំណត់ដោយមាត្រា ៣១៨ នៃក្រមនេះ[19]។ មាត្រានេះ បានផ្តល់ឱ្យចៅក្រមជំនុំជម្រះមាន ឆន្ទានុសិទ្ធិដោយមិនចាំបាច់បើកសវនាការតទល់សាក្សី ទាក់ទងនឹងភ័ស្តុតាងទេ ប្រសិនបើសវនាការ បែបនោះនាំឱ្យមានការពន្យារពេលដោយមិនចាំបាច់ ដល់ការស្វែងរកការបញ្ជាក់ការពិត។ ហេតុដូច្នេះ មាត្រានេះអនុញ្ញាតឱ្យអង្គជំនុំជម្រះមិនចាំបាច់ឱ្យមានការតទល់គ្នាជាមួយនឹងសាក្សី មួយចំនួននោះទេ[20]។ សំណើដែលមានលក្ខណៈទូលំទូលាយរបស់ជនជាប់ចោទសុំតទល់ជាមួយ សាក្សីទាំងអស់ដែលបានផ្តល់ចម្លើយ នឹងធ្វើឱ្យប៉ះពាល់ដោយមិនចាំបាច់ដល់សិទ្ធិទទួលបានការជំនុំ ជម្រះឆាប់រហ័ស និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព[21]។ ប៉ុន្តែវាជាកត្តាចាំបាច់ក្នុងការ ធានាថា ឯកសារជាលាយលក្ខណ៍អក្សរដែលត្រូវបានប្រមូលតាមរយៈការស៊ើបអង្កេតយូរមកហើយ គឺមិនចាំបាច់ត្រូវធ្វើឡើងជាន់គ្នា តាមរយៈសិទ្ធិដាច់ខាត និងមិនចាំបាច់ក្នុងការតទល់គ្នាជាមួយ សាក្សីនោះទេ[22]។

១៤ ក្រុមមេធាវីការពារក្តី លើកឡើងថា មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៨៤ (១) នៃវិធានផ្ទៃក្នុង បានផ្តល់សិទ្ធិដាច់ខាតក្នុងការតទល់នឹងសាក្សីបដិបក្ខ ដែលពីមុនមកជនជាប់ ចោទមិនទាន់បានតទល់ជាមួយនឹងសាក្សីទាំងនោះនៅឡើយ[23]។ ការមិនមានបទប្បញ្ញត្តិច្បាស់ លាស់ សម្រាប់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី មិនមានន័យថាវិធាន

---

[18] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៩-៤០; *សូមមើលផងដែរ* ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣២; ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៩។

[19] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧, ១៥។

[20] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៣-១៥; *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[21] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៨-៣០; *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩, ១១-១២, ១៤, ១៨-១៩។

[22] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៦។

[23] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៣-៥; ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤-៦; ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៦, ១០; ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣-៦។

ផ្ទៃក្នុងមានភាពខ្វះចន្លោះនោះទេ។ ដោយសារតែការមិនមានចែងអំពីបទប្បញ្ញត្តិច្បាស់លាស់ មិនបញ្ជាក់ថា មានភាពមិនច្បាស់លាស់ និងភាពមិនស៊ីសង្វាក់នឹងបទដ្ឋានអន្តរជាតិទេនោះ ការសំអាងលើវិធាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ មិនមែនជាការចាំបាច់នោះឡើយ[24]។ សិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់នឹងសាក្សីដែលផ្តល់សក្ខីកម្មប្រឆាំងខ្លួនគាត់ គឺជាសិទ្ធិសារវ័ន្តដើម្បីទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលសិទ្ធិនេះត្រូវបានធានាដោយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុប ដែលដកស្រង់ដោយសហព្រះរាជអាជ្ញា បានគាំទ្រទស្សនៈដែលថា ការកំហិតសិទ្ធិដើម្បីកោះហៅសាក្សីឲ្យតទល់នៅក្នុងសវនាការ ជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ឬមិនអាចយកមកអនុវត្តបាន[25]។

១៥ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង មិនទទួលស្គាល់សិទ្ធិដាច់ខាតណាមួយដើម្បីធ្វើការតទល់សាក្សីនោះទេ អង្គជំនុំជម្រះត្រូវតែពិចារណាអំពីភាពអាចទទួលយកបាន និងការថ្លឹងថ្លែងឲ្យបានគ្រប់គ្រាន់ ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយផ្អែកលើមួយករណីម្តងមួយករណីម្តង[26]។ នៅត្រឹមកម្រិតអប្បបរមា ការសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយមិនធ្វើការសួរដេញដោលសាក្សី នឹងត្រូវធ្វើសម្រាប់តែករណីពិសេស និងត្រូវគោរពលក្ខខណ្ឌតឹងរ៉ឹង[27]។ កំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនអាចចាត់ទុកជាចម្លើយសាក្សី ហើយទទួលយកជាភ័ស្តុតាងនោះទេ ដោយសារតែមេធាវីការពារក្តីមិនអាចតទល់នឹងសាក្សី

---

[24] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១២-១៤; ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៣-៤; ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤០-៤១។

[25] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៤, ១៦; ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៧; ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៥, ២៣-៣៧។

[26] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ២២-២៧; ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១១; ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣០-៣១។

[27] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣០; ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៩-១១ (គួរចាត់ទុកថាសាក្សីមួយមិនអាចផ្តល់សក្ខីកម្មបាន ប្រសិនបើសាក្សីនោះបានស្លាប់បាត់បង់ជីវិត ពិការភាពផ្នែកផ្លូវកាយ ឬផ្លូវចិត្តមិនអាចផ្តល់សក្ខីកម្មបាន ឬត្រូវបានការពារដោយអភ័យឯកសិទ្ធិច្បាប់ដែលត្រូវបានទទួលស្គាល់ ប៉ុន្តែគួរចាត់ទុកថាអាចផ្តល់សក្ខីកម្មបានប្រសិនបើសាក្សីរូបនោះគ្រាន់តែបដិសេធមិនព្រមបង្ហាញខ្លួន); ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៩ (ចម្លើយដែលត្រូវបានទទួលយកដោយតុលាការ ICTY និង SCSL មានទំនាក់ទំនងជាធម្មតាជាមួយនឹងភ័ស្តុតាងនៃទីតាំងឧក្រិដ្ឋកម្ម ខណៈដែលចម្លើយដែលនឹងបញ្ជាក់ពីទង្វើ ឬការប្រព្រឹត្តរបស់ជនជាប់ចោទត្រូវបានដកចេញ)។

នៅពេលដែលសាក្សីទាំងនោះផ្តល់ចម្លើយ និងដោយសារតែកំណត់ហេតុទាំងនេះ ត្រូវបានចោទប្រកាន់ថា បានដកចេញដោយមិនត្រឹមត្រូវនូវភស្តុតាងដោះបន្ទុក និងខ្វះភាពអនាគតិ ឬភាពត្រឹមត្រូវ[28]។ ដោយផ្អែកលើសំអាងហេតុដូចគ្នានេះ ចម្លើយដែលប្រមូលបានដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនអាចជឿជាក់បាន ហើយមិនគួរដាក់បញ្ចូលជាភស្តុតាងនោះទេ ប្រសិនបើមិនមានការទទួលស្គាល់នូវសិទ្ធិតទល់គ្នានឹងសាក្សី[29]។

១៦ ជាការឆ្លើយតប និងទោះបីជាទទួលស្គាល់អំពីភាពខុសគ្នានៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនក៏ដោយ ក៏សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា ករណីនេះមិននាំឱ្យមានតម្រូវការជាស្វ័យប្រវត្តិថា រាល់សាក្សីទាំងអស់ត្រូវតែមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការនោះទេ[30]។

## ៤. សំអាងហេតុ

### ៤.១. ក្របខ័ណ្ឌច្បាប់

១៧ វិធានផ្ទៃក្នុងពុំបានចែងអំពីបទប្បញ្ញត្តិ ដូចគ្នាទៅនឹងបទប្បញ្ញត្តិរបស់តុលាការ ICTY ដូចជា វិធាន ៩២*ស្ទួន* និងវិធាន ៩២*ស្ទួនបី* ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការពិចារណាអំពីភាពអាចទទួលយកបាននៃគ្រប់ភស្តុតាងទាំងអស់ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅពេលដែលភស្តុតាងទាំងនោះមានភាពជាប់ពាក់ព័ន្ធ និងមានតម្លៃជាភស្តុតាង ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។ វិធាន ៨៧(១)

---

[28] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ២២-២៧; ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣-១៧; ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១២។

[29] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ២២-២៤; ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១២; ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤៧; *សូមមើលផងដែរ* “សារណារបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់សម្ភារៈទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូល” ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E59។ មេធាវីការពារក្តីចំនួនពីរក្រុមបានស្នើបន្ថែមសុំឱ្យមានសវនាការផ្ទាល់មាត់ទៅលើបញ្ហាទាំងនេះ ដែលមានសំណើមួយអង្គជំនុំជម្រះចាត់ទុកថាមានសុពលភាព ដោយអង្គជំនុំជម្រះបានកោះហៅប្រធាន និងអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាមកផ្តល់សក្ខីកម្ម ទាក់ទិននឹងការរៀបចំបណ្ណសារ និងទម្លាប់នៃការប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ប្រតិចារឹក ថ្ងៃទី ២៣២៥ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅដារ៉ា) និងថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាំង យុ) បន្ថែមទៅលើសវនាការមួយចំនួនទៀតទៅលើបញ្ហាឯកសារដែលអង្គជំនុំជម្រះបានធ្វើមកដល់បច្ចុប្បន្ន) (*សូមមើលឧទាហរណ៍* ឯកសារ E170)។

[30] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥-៣៨, ៤០។

នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ គោលការណ៍ទូទៅនេះត្រូវបានកំណត់ ដោយអនុវិធាន ៨៧(៣) ដែលចែងថា "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ ក) មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ) ច្បាប់ មិនអនុញ្ញាត ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។ ភស្តុតាងដែលបានស្នើឡើងទាំងអស់ ដែលបានបំពេញនូវលក្ខណវិនិច្ឆ័យទាំងនេះត្រូវបានពិចារណាថាអាចទទួលយកបាន ដូច្នេះអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន អនុលោមតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក[31]។ អនុលោមតាមក្របខ័ណ្ឌនេះ អង្គជំនុំជម្រះនឹងផ្អែកទៅលើលក្ខណវិនិច្ឆ័យអំពីភាពអាចទទួលយកបាននៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដើម្បីធ្វើការសម្រេចថាតើ កំណត់ហេតុស្តាប់ចម្លើយ (រួមទាំងឧបសម្ព័ន្ធ) ឬប្រតិចារឹកទាំងឡាយដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយពុំមានការតទល់នៅក្នុងសវនាការនោះ "ត្រូវបានច្បាប់អនុញ្ញាត" ដែរ ឬទេ ហើយស្ថិតនៅក្រោមលក្ខខណ្ឌមួយណា (វិធាន ៨៧(៣)(ឃ)) នៃវិធានផ្ទៃក្នុង។ នៅពេលដែលភស្តុតាងនេះ ត្រូវបានរកឃើញថាអាចទទួលយកបាននោះ អង្គជំនុំជម្រះនឹងយកលក្ខណវិនិច្ឆ័យទាំងនេះមកប្រើផងដែរ ដើម្បីធ្វើការវាយតម្លៃអំពីតម្លៃជាភស្តុតាងនៃភស្តុតាងនេះ។

១៨ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងការ "តទល់ ឬបានតទល់សាក្សីដាក់បន្ទុក"[32] ចំណែកឯច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ធានានូវសិទ្ធិរបស់ជនជាប់

---

[31] "សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត" ឯកសារលេខ E190 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ") កថាខណ្ឌ ១៨ (ដែលបញ្ជាក់ថា ភស្តុតាងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវបានចុះលេខជាប្រភេទឯកសារ E3 នៅពេលដែលអង្គជំនុំជម្រះបដិសេធការជំទាស់ណាមួយទៅនឹងឯកសារនេះ អនុលោមតាមលក្ខណៈវិនិច្ឆ័យនៃវិធានផ្ទៃក្នុង ៨៧(៣))។

[32] "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងចូលជាធរមាន នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ("កិច្ចព្រមព្រៀង") មាត្រា ១៣(១)។

ចោទក្នុងការ "ពិនិត្យភ័ស្តុតាងដាក់បន្ទុក"[33]។ ទោះបីជាមានភាពមិនស៊ីសង្វាក់គ្នាមួយចំនួនរវាងសំណៅទាំងបីភាសានៃវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ក៏ដោយ ក៏មានតែសំណៅភាសាអង់គ្លេសប៉ុណ្ណោះ ដែលចែងថាសិទ្ធិរបស់ជនជាប់ចោទក្នុងការកោះហៅសាក្សីជាសិទ្ធិដាច់ខាត[34]។ ទោះបីជាមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ" យ៉ាងណាក៏ដោយ ក៏មាត្រា៣១៨ នៃក្រមដដែលនេះ ផ្តល់អំណាចឱ្យប្រធានសវនាការអាចបដិសេធចេញពីការពិភាក្សាដេញដោល នូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះ ដោយឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសម្តែងឱ្យឃើញការពិត"។ ហេតុដូច្នេះ ច្បាប់កម្ពុជាទទួលស្គាល់ឆន្ទានុសិទ្ធិរបស់ប្រធានសវនាការក្នុងការបដិសេធពុំស្តាប់សាក្សី ដែលភ័ស្តុតាងរបស់សាក្សីនោះ ត្រូវបានយល់ឃើញថា មិនជាប់ពាក់ព័ន្ធ ជាន់គ្នាទៅលើភ័ស្តុតាងផ្សេងៗទៀតនៅចំពោះមុខអង្គជំនុំជម្រះ ឬក៏ទំនងជាអាចពន្យារកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ដោយសារតែភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២ បានស្នើឱ្យស្តាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលមានចំនួនសរុបទាំងអស់ ១០៥៨ នាក់នោះ ការកំរិតសិទ្ធិក្នុងការស្តាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងទាំងអស់ គឺជាការចាំបាច់ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះទោសឱ្យបានឆាប់រហ័ស។

១៩ មាត្រា ១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) (ដែលមាត្រា ១២ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានយោងទៅរកនោះ) ក៏មិនបានចែងអំពីសិទ្ធិគ្មានដែនកំណត់ក្នុងការស្នើសុំឱ្យសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តីមកបង្ហាញខ្លួននៅក្នុងសវនាការនោះឡើយ។ មាត្រានេះគ្រាន់តែចែងថា ជនជាប់ចោទត្រូវបានផ្តល់នូវឱកាសមួយសមស្របក្នុងការសួរសំណួរ

---

[33] "ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ៣៥ថ្មី(ង)។

[34] សំណៅជាភាសាអង់គ្លេសនៃវិធានផ្ទៃក្នុង ៨៤(១) ចែងថា "[t]he Accused shall have the absolute right to summon witnesses against him or her whom the Accused had no opportunity to examine during the pre-trial stage."។ សំណៅជាភាសាខ្មែរនៃវិធានផ្ទៃក្នុងនេះចែងថា "ជនជាប់ចោទមានសិទ្ធិស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុក ដែលជនជាប់ចោទមិនទាន់មានឱកាសតទល់ នៅដំណាក់កាលមុនពេលជំនុំជម្រះ"។ ចំណែកឯសំណៅជាភាសាបារាំងនៃវិធាននេះចែងថា "[t]he Accused shall have the right to require the attendance at trial of any witness in respect of whom the Accused has not had the opportunity of a confrontation at the pre-trial stage/during the judicial investigation".

និងតទល់ជាមួយនឹងសាក្សីដាក់បន្ទុក នៅក្នុងដំណាក់កាលខ្លះនៃកិច្ចដំណើរការនីតិវិធី[35]។ ក្របខ័ណ្ឌច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ និងតុលាការដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្មនានា ក៏បានចង្អុលបង្ហាញថា សិទ្ធិក្នុងការកោះហៅសាក្សីនៅពេលសវនាការ គឺមិនមែនជាសិទ្ធិដាច់ខាតឡើយ ហើយការទទួលយកភ័ស្តុតាងដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ត្រូវបានទទួលយកនៅចំពោះមុខតុលាការទាំងនេះ ជាមធ្យោបាយមួយនៃការអនុវត្តការជំនុំជម្រះក្តីលើឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ប្រកបដោយប្រសិទ្ធភាពសមស្រប ដែលត្រូវស្ថិតនៅក្រោមការការពារមួយចំនួន ដើម្បីធានានូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី[36]។

---

[35] មាត្រា ១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, 999 U.N.T.S. 171 ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២ (“ICCPR”) ចែងអំពីសិទ្ធិរបស់ជនជាប់ចោទ “ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក”។ សូមមើលសេចក្តីអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លេខ 32 (90) ត្រង់មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាក្តីនានា និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ឯកសារអង្គការសហប្រជាជាតិ លេខ CCPR/C/GC/32 កថាខណ្ឌ ៣៩។ រឿងក្តី *Lassâad Aouf* ទល់នឹង ប្រទេសបែលហ្ស៊ិក, Comm. No. 1010/2001 ទស្សនៈគណៈកម្មាធិការសិទ្ធិមនុស្ស ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៩.៣ និង (ទាក់ទិននឹងការការពារស្រដៀងគ្នាយ៉ាងខ្លាំងនៅក្នុងមាត្រា ៦(៣)(ឃ) នៃអនុសញ្ញាអឺរុបសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (“ECHR”)), ETS 5/213 UNTS 222 ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ រឿងក្តី *Delta* ទល់នឹង ប្រទេសបារាំង សាលក្រម, ECHR (no. 11444/85), ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩០ កថាខណ្ឌ ៣៦។ រឿងក្តី *Unterpertinger* ទល់នឹង ប្រទេសអូស្ត្រាលី, ECHR (no. 9120/80) ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ កថាខណ្ឌ ៣១ និង រឿងក្តី *A.S.* ទល់នឹង ប្រទេសហ្វាំងឡង់ សាលក្រម, ECHR (no. 40156/07) ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣។

[36] វិធាន ៩២*ស្ទួន*(ក) នៃវិធានស្តីពីនីតិវិធីនិងភ័ស្តុតាងរបស់តុលាការ ICTY ចែងថា “អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកទាំងស្រុង ឬមួយផ្នែកនូវភ័ស្តុតាងរបស់សាក្សីណាម្នាក់ក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ជាការជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ដែលត្រូវប្រើធ្វើជាតឹកតាងលើបញ្ហាអ្វីមួយ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ”។ សូមមើល ផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Martić* សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់ នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភ័ស្តុតាងរបស់សាក្សីឈ្មោះ Milan Babić អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-11-AR73.2) ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១២-១៤ និង ១៨-១៩ និងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Milosević* សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដែលស្នើសុំឱ្យយល់ព្រមទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយអនុលោមតាមវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY Trial Chamber (IT-02-54-T) ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០២, សេចក្តីប្រកាសរបស់ចៅក្រម O-Gon Kwon កថាខណ្ឌ ៣ (កត់សម្គាល់ថា វិធីសាស្ត្របត់បែនជាងមុនក្នុងការទទួលយកចម្លើយសាក្សីនានា បង្កើននូវសមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់ចែងគ្រប់គ្រងសវនាការដែលមានខ្នាតធំបានដោយមានប្រសិទ្ធភាពជាងមុន ដែលនោះគឺជាការអនុវត្តជាទូទៅក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី

## ៤.២ លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយក និងការវាយតម្លៃអំពីតម្លៃជាភស្តុតាង ដែលត្រូវបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក

២០ ក្របខ័ណ្ឌច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ និងតុលាការដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្មនានា បានថ្លឹងថ្លែងទៅលើកត្តាមួយចំនួន នៅពេលធ្វើការសម្រេចថាតើត្រូវទទួលយក ឬមិនទទួលយកភស្តុតាងនៅក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក ដោយមិនចាំបាច់តម្រូវឱ្យមានវត្តមានសាក្សីផ្តល់ចម្លើយ ឬអ្នកធ្វើប្រតិចារឹកទាំងនោះនៅក្នុងតុលាការឡើយ។ នៅក្នុងបរិបទនៃការជំនុំជម្រះឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ អង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើវិធាន និងយុត្តិសាស្ត្រទាំងនេះ ដើម្បីបង្កើតឱ្យមាននូវតុល្យភាពមួយសមស្រប រវាងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ជាពិសេសទាក់ទិនទៅនឹងដំណើរការឆាប់រហ័សនៃការជំនុំជម្រះក្តី[37]។

### *៤.២.១. ភស្តុតាងដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក ដែលផ្តល់សក្ខីកម្មអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

២១ នៅពេលដែលកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក ផ្តល់សក្ខីកម្មអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ វិធាននានាដែលបង្កើតឡើងនៅកម្រិតអន្តរជាតិបង្ហាញថា ការផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកទាំងនេះ ជាទូទៅត្រូវបានច្រានចោលជាមុន លើកលែងតែមេធាវីការពារក្តីត្រូវបានផ្តល់នូវឱកាសតទល់គ្នា[38]។ យុត្តិសាស្ត្រ និងក្របខ័ណ្ឌច្បាប់របស់តុលាការ*មិនអចិន្ត្រៃយ៍*នានា មាន

---

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ ហើយថា ចៅក្រមអាជីពមានសមត្ថភាពក្នុងការសម្រេចអំពីទម្ងន់ដ៏សមស្របដែលត្រូវផ្តល់ទៅឱ្យភស្តុតាងប្រភេទនេះ)។ មាត្រា ៦៧(១)(ង) នៃលក្ខន្តិកៈទីក្រុងរ៉ូម ក៏មិនបានចែងកំណត់សិទ្ធិក្នុងការស្តាប់សាក្សីថាជាសិទ្ធិដាច់ខាតនោះឡើយ ("ក្នុងការកំណត់បទចោទប្រកាន់ណាមួយ ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាននូវ [...] ការធានាជាអប្បរមាដោយសមភាពបំផុត ដូចតទៅនេះ៖ (ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក")។

[37] សូមមើលមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ថ្មី(១) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[38] សូមមើល ឧទាហរណ៍ វិធាន ៩២*ស្ទួន ស្ទួនពីរ* និង*ស្ទួនបី* របស់តុលាការ ICTY និងតុលាការ SCSL និងវិធាន ៩២*ស្ទួន*(ក)-(ង) របស់តុលាការ ICTR ។

ចេតនាទាត់ចោលនូវកំណត់ហេតុនានា ដែលជួយដល់ការបង្ហាញភ័ស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ (ប៉ុន្តែមិនមែនកំណត់ហេតុទាំងឡាយណាដែលពាក់ព័ន្ធ នឹងបញ្ហានានា ក្រៅពីបញ្ហាដែលទាក់ទិននឹងការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទឡើយ ដូចជាគោលនយោបាយទូទៅ រចនាសម្ព័ន្ធទំនាក់ទំនង និងអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួម)[39] ដោយហេតុផលថា ការផ្តន្ទាទោសដោយផ្អែក ឬក្នុងវិសាលភាពតែទៅលើកំណត់ហេតុនានា ដែលមេធាវីការពារក្តីមិនត្រូវបានផ្តល់នូវឱកាសគ្រប់គ្រាន់ និងសមស្របដើម្បីធ្វើការតទល់គ្នានោះ អាចរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌[40]។

---

[39] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Haradinaj* និងអ្នកផ្សេងទៀត សេចក្តីសម្រេចលើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើឱ្យយល់ព្រមទទួលយកប្រតិចារឹកនៃភ័ស្តុតាងមួយចំនួន ជាជំនួសឱ្យចម្លើយដោយផ្ទាល់មាត់ អនុលោមតាមវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY (IT-04-84*bis*-PT) ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើរឿងក្តី *Haradinaj*") កថាខណ្ឌ ២០ (បញ្ជាក់ថា "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" គឺជាសំដីនិយាយបែបសាមញ្ញដែលគួរតែត្រូវបានផ្តល់ន័យទៅតាមន័យធម្មតារបស់វាថា ៖ អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ រួមទាំងអំពើអកម្ម នៅក្នុងករណីសមស្រប។ អាកប្បកិរិយា រួមបញ្ចូលផងដែរនូវស្ថានភាពផ្នែកស្មារតីដែលពាក់ព័ន្ធរបស់ជនជាប់ចោទ ព្រមទាំងការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម)។ សូមមើលបន្ថែមទៀត រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Miloševi* សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំឱ្យយល់ព្រមទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-54-T) ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ២២ (ដោយមិនរាប់បញ្ចូលនៅក្នុងសញ្ញាណនេះនូវអំពើ និងការប្រព្រឹត្តិរបស់ជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថាជា សហចារី អ្នកនៅក្រោមបង្គាប់ និងអ្នកផ្សេងៗទៀត)។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Galić* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ទាក់ទិននឹងវិធាន ៩២ស្ទួន(គ) អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-29-AR73.2) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១០, ១៣, ១៦។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Karadžić* សេចក្តីសម្រេចលើញត្តិស្នើសុំលើកទី៣ របស់រដ្ឋអាជ្ញាដែលស្នើឱ្យយល់ព្រមទទួលយកនូវចម្លើយ និងប្រតិចារឹកនៃភ័ស្តុតាងមួយចំនួន ជាជំនួសឱ្យចម្លើយដោយផ្ទាល់មាត់ អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់ឱ្យសាលាក្រុង Sarajevo) អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-PT) ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៥។

[40] សូមមើល ឧទាហរណ៍ វិធាន ៩២*ស្ទួន*បី (ខ) របស់តុលាការ ICTY ("ប្រសិនបើភ័ស្តុតាងផ្តល់សក្ខីកម្មអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះអាចជាកត្តាមួយដែលប្រឆាំងនឹងការទទួលយកភ័ស្តុតាងបែបនេះ [...]") និងវិធាន ៩២*ស្ទួន*(ឃ) នៃតុលាការ ICTR ("[ក] អង្គជំនុំជម្រះអាច ទទួលយកប្រតិចារឹកនៃភ័ស្តុតាង ដែលផ្តល់ឱ្យដោយសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការ ដែលផ្តល់សក្ខីកម្មអំពីបញ្ហាណាមួយ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ")។ សូមមើល ផងដែរ វិធាន ៩២*ស្ទួន*(ក)(ii) នៃតុលាការ ICTY (បញ្ជាក់ថា ភ័ស្តុតាងនៅក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយតែមួយប៉ុណ្ណោះ និងមិនត្រូវទទួលយកឡើយ នៅពេលដែល ក) មានផលប្រយោជន៍សាធារណៈដ៏លើសលប់ នៅក្នុងភ័ស្តុតាងដែលត្រូវបង្ហាញដោយផ្ទាល់មាត់។ ខ) ភាគីជំទាស់អាចបង្ហាញបានថា ចរិតលក្ខណៈ ឬប្រភពរបស់វា មិនអាចធ្វើឱ្យគេទុកចិត្តវាបាន។ ឬ គ) មានកត្តាផ្សេងៗទៀត ដែលធ្វើឱ្យវា

២២ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក អង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយ ឬ ប្រតិចារឹក ដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាប់ពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយា របស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបាន ចាត់ទុកថា "ច្បាប់មិនអនុញ្ញាតឡើយ" អនុលោមតាមវិធានផ្ទៃក្នុង ៨៧(៣)(ឃ) និងមិនអាច ទទួលយកបានឡើយសម្រាប់គោលបំណងនេះ លើកលែងតែកំណត់ហេតុ ឬប្រតិចារឹកមួយចំនួន ដែលមានបង្ហាញនៅខាងក្រោមនេះ ឬលើកលែងតែមេធាវីការពារក្តីត្រូវបានផ្តល់នូវឱកាសក្នុង ការពិនិត្យសាក្សីផ្តល់ចម្លើយទាំងនេះនៅក្នុងសវនាការ។

### *៤.២.២. កត្តានានាដែលគាំទ្រដល់ការទទួលយកភស្តុតាង និងការផ្តល់នូវតម្លៃជាភស្តុតាង និងដែល មានទម្ងន់ចំពោះភស្តុតាង ដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក*

២៣ នៅពេលដែលកំណត់ហេតុផ្តល់សក្ខីកម្មអំពីបញ្ហានានា ក្រៅពីអំពើ ឬអាកប្បកិរិយារបស់ជនជាប់ ចោទ (និង*តាមការវិភាគបឋម* ត្រូវបានយល់ឃើញថាជាប់ពាក់ព័ន្ធ គួរឱ្យជឿជាក់បាន ឬមិនត្រូវ បានបដិសេធចោលដោយលក្ខណវិនិច្ឆ័យនៃវិធាន ៨៧(៣)) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងទទួល យកភស្តុតាងរបស់បុគ្គលដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក ដោយមិន ចាំបាច់តម្រូវឱ្យមានវត្តមានរបស់ពួកគាត់នៅក្នុងសវនាការឡើយ ហើយនៅក្រោមលក្ខខណ្ឌ មួយចំនួន អាចផ្អែកទៅលើឯកសារនេះ។

២៤ អនុលោមតាមការអនុវត្ត និងវិធាននានានៅកម្រិតអន្តរជាតិដែលពាក់ព័ន្ធ កត្តាដែលគាំទ្រដល់ ការទទួលយកភស្តុតាង និងការផ្តល់នូវតម្លៃជាភស្តុតាងមួយចំនួន និងដែលមានទម្ងន់ចំពោះ ភស្តុតាងដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក រួមមានថាតើ ភស្តុតាងនេះ៖

---

មានលក្ខណៈសមស្របចំពោះសាក្សីរូបនោះចូលមកបង្ហាញខ្លួនសម្រាប់ការសាកសួរសាក្សីបដិបក្ខ) និងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Popović* និងអ្នកផ្សេងទៀត សេចក្តីសម្រេចលើញត្តិសម្ងាត់ របស់រដ្ឋអាជ្ញាដែលស្នើឱ្យយល់ព្រមទទួលយក ភស្តុតាង ជាលាយលក្ខណ៍អក្សរ ជាជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់ អនុលោមតាមវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY (IT-05-88-T) ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចលើរឿងក្តី *Popović*") កថាខណ្ឌ ១៦។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blagojević* និង *Jokić*, សេចក្តីសម្រេចលើកទី១លើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើសុំឱ្យយល់ព្រម ទទួលយកនូវចម្លើយសាក្សី និងសក្ខីកម្មពីមុនៗ អនុលោមតាមវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60-T) ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ ២៦។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Sikirica* និងអ្នកផ្សេងទៀត សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំឱ្យទទួលយកប្រតិចារឹក អនុលោមតាមវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូង នៃ តុលាការ ICTY (IT-95-8-T) ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៤។

ក) មានចរិតលក្ខណៈត្រួតគ្នា ដែលនៅក្នុងនោះសាក្សីដទៃទៀតនឹងផ្តល់ ឬបានផ្តល់រួចហើយនូវសក្ខីកម្មផ្ទាល់មាត់លើអង្គហេតុស្រដៀងគ្នា។

ខ) មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលពាក់ព័ន្ធទៅនឹងភ័ស្តុតាងនៃកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ឬផ្តល់សក្ខីកម្មអំពីកម្រិតធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ឬចរិតលក្ខណៈនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ)។

គ) មានការវិភាគមួយជាទូទៅ ឬជាស្ថិតិ ស្តីពីសមាសភាគជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានា ដែលមានការទាក់ទងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ឃ) ពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ។

ង) មិនអាចដាក់ឲ្យស្ថិតនៅក្រោមការតទល់គ្នា ពីព្រោះក្រោយមក សាក្សីផ្តល់ចម្លើយនោះបានស្លាប់ ឬមិនអាចតាមរកឃើញ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងសមស្របក៏ដោយ ឬមានបញ្ហាសុខភាពដែលមិនអាចមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់បាន[41]។

២៥ នៅពេលដែលភ័ស្តុតាងនៅក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក ត្រូវបានអនុញ្ញាតឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមិនចាំបាច់តម្រូវឲ្យមានវត្តមានសាក្សីផ្តល់ចម្លើយទាំងនោះនៅសវនាការ អនុលោមតាមលក្ខណវិនិច្ឆ័យទាំងនេះ អង្គជំនុំជម្រះនៅក្នុងពេលសមស្របត្រូវវាយតម្លៃថាតើត្រូវផ្តល់ឲ្យភ័ស្តុតាងប្រភេទនេះនូវតម្លៃជាភ័ស្តុតាង និងទម្ងន់ត្រឹមណា ប្រសិនបើមាន។ ការពុំមានសក្ខីកម្មដោយផ្ទាល់មាត់ និងឱកាសតទល់គ្នា គឺជាការពិចារណាមួយដែល

---

[41] សូមមើល ឧទាហរណ៍ វិធាន ៩២*ស្ទួន*(ក)(i)(ក)-(ឃ) និង ៩២*ស្ទួនបី*(ក) នៃតុលាការ ICTY និង វិធាន៩២*ស្ទួន*(ក)(i)(ក)-(ឃ), (គ)-(ង) នៃតុលាការ ICTR។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blagojević* និង *Jokić*, សេចក្តីសម្រេចលើកទី១លើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា ដែលស្នើសុំឲ្យយល់ព្រមទទួលយកនូវចម្លើយសាក្សី និងសក្ខីកម្មពីមុនៗ អនុលោមតាមវិធាន ៩២*ស្ទួន* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60-T) ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ ១២, ២០, ២៨។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Naletilić* សេចក្តីសម្រេចស្តីពីសេចក្តីជូនដំណឹងរបស់រដ្ឋអាជ្ញាស្តីពីការមានបំណងចង់ផ្តល់ជូននូវប្រតិចារឹកមួយចំនួន អនុលោមតាមវិធាន ៩២*ស្ទួន*(ឃ) IT-98-34-PT ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៧-១២។

ពាក់ព័ន្ធនៅក្នុងបញ្ហានេះ មានន័យថា តម្លៃជាភស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅឱ្យភស្តុតាងបែបនេះ អាចត្រូវបានកម្រិតនៅក្នុងកាលៈទេសៈជាច្រើន[42]។

## ៤.៣. ការវាយតម្លៃអំពីប្រភេទនៃភស្តុតាងមួយចំនួនដែលបានស្នើឡើង ទាក់ទិនទៅនឹងសេចក្តីសម្រេចនេះ

### *៤.៣.១. កំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗរបស់ ក.ស.ច.ស ដែលមិនត្រូវបាន កោះហៅឱ្យមកផ្តល់សក្ខីកម្មនៅពេលសវនាការ*

២៦ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា កំណត់ហេតុដែលធ្វើឡើងក្នុងអំឡុងកិច្ចស៊ើបសួរត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[43]។ នៅពេលដែលមានការចោទប្រកាន់អំពីភាពខ្វះចន្លោះនៅក្នុងកំណត់ហេតុទាំងនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ប្រការនេះនឹងត្រូវបានពិចារណា នៅពេលដែលមានការចង្អុលបង្ហាញច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ និងមានភាពពាក់ព័ន្ធជាក់ស្តែងទៅនឹងសវនាការតែប៉ុណ្ណោះ[44]។ មានការផ្តល់ជូននូវការការពារបន្ថែមទៀត ដោយហេតុថា សាក្សីដែលត្រូវបានកោះហៅឱ្យមកផ្តល់ភស្តុតាងនៅសវនាការ អាចត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ ឬគ្រប់ភាគីទៅលើខ្លឹមសារនៃកំណត់ហេតុពីមុនរបស់ពួកគាត់[45]។

---

[42] សូមមើល ឧទាហរណ៍ រឿងក្តី *Asch* ទល់នឹង ប្រទេសអូទ្រីស សាលក្រម របស់ ECHR (លេខ 12398/86) ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩១ កថាខណ្ឌ ២៧, ៣១ និងរឿងក្តី *A.S.* ទល់នឹង ប្រទេសហ្វាំងឡង់ សាលក្រម របស់ ECHR (លេខ 40156/07) ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤ (បញ្ជាក់ថា ការផ្តន្ទាទោសមិនគួរផ្អែកត្រឹមតែ ឬក្នុងកម្រិតដាច់ខាតទៅលើកំណត់ហេតុស្តាប់ចម្លើយ ដែលមេធាវីការពារក្តីពុំមានលទ្ធភាពតទល់នោះឡើយ) និងសេចក្តីសម្រេចលើរឿងក្តី *Popović* កថាខណ្ឌ ៦៦ ("អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណា [...] ការពុំមានឱកាសក្នុងការសួរដេញដោលនៅក្នុងសវនាការនាពេលនេះ នៅពេលធ្វើការវាយតម្លៃ [...] ភស្តុតាង និងសម្រេចទៅលើទម្ងន់ ដែលជាប់ពាក់ព័ន្ធទៅនឹងប្រតិចារឹក [ត្រូវបានទទួលយក អនុលោមតាមវិធាន ៩២*ស្ទួរបី* នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTY] អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការ")។

[43] សេចក្តីសម្រេចលើឯកសារដែលបានស្នើសុំ កថាខណ្ឌ ២០។ សេចក្តីសម្រេចទាក់ទងនឹងកំណត់ហេតុជាសំឡេង កថាខណ្ឌ ៦-១៥។ "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងសូចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន ៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្តាហ៍ដំបូង" ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E158 កថាខណ្ឌ ១៨១-១៨៥។

[44] សេចក្តីសម្រេចទាក់ទងនឹងកំណត់ហេតុជាសំឡេង កថាខណ្ឌ ១២។

[45] សេចក្តីសម្រេចទាក់ទងនឹងកំណត់ហេតុជាសំឡេង កថាខណ្ឌ ១៣។

២៧ នៅពេលដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗរបស់ ក.ស.ច.ស ទៅលើសាក្សីដែលមិនត្រូវបានកោះហៅឲ្យផ្តល់ភ័ស្តុតាងនៅពេលសវនាការ ត្រូវបានស្នើសុំឲ្យដាក់ជំនួសវិញនៅចំពោះមុខអង្គជំនុំជម្រះ ដោយមិនមានវត្តមានរបស់សាក្សីផ្តល់ចម្លើយនោះទេ មេធាវីការពារក្តីត្រូវបានផ្តល់ឲ្យនូវសិទ្ធិដែលមានតម្លៃស្មើគ្នា ដើម្បីធ្វើការជំទាស់ដែលពាក់ព័ន្ធទៅនឹងសម្ភារៈនេះ ប្រសិនបើមាន (ផ្នែក ៤.៤)។ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះអាចមានតម្លៃជាភ័ស្តុតាង ឬមានទម្ងន់ជាភ័ស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមាន ដោយសារតែកង្វះឱកាសដើម្បីតទល់គ្នា ឬដោយសារមានចំណុចខ្វះខាតជាសារវន្តនានានៅក្នុងកំណត់ហេតុ ឬប្រតិចារឹកទាំងអស់នេះត្រូវបានលើកឡើង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬភាពគួរឲ្យជឿជាក់បាន។

២៨ នៅក្នុងសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះ ឯកសារទាំងឡាយ ឬភ័ស្តុតាងផ្សេងទៀត ដែលបានរៀបរាប់នៅក្នុងជើងទំព័រនៃផ្នែកនានាដែលពាក់ព័ន្ធ នៅក្នុងដីកាដំណោះស្រាយ ត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន ដោយហេតុថា ទម្ងន់ជាភ័ស្តុតាង មួយចំនួនត្រូវបានផ្តល់ទៅលើឯកសារទាំងឡាយ ដោយសហចៅក្រមស៊ើបអង្កេត[46]។ អង្គជំនុំជម្រះ ទទួលស្គាល់ថាភស្តុតាងដែលមានបញ្ចូលនៅក្នុងឯកសារទាំងឡាយដែលត្រូវបានសន្មតនេះ (និងក្រោយមក ត្រូវបានផ្តល់ចំណាត់ថ្នាក់ជាឯកសារ E3) គឺជាចម្លើយមួយចំនួនរបស់សាក្សីនីមួយៗដែលមិនត្រូវបានកោះហៅឲ្យមកផ្តល់ភ័ស្តុតាងនៅពេលសវនាការ និងដែលភ័ស្តុតាងរបស់ពួកគាត់អាចមិនមែនជាកម្មវត្ថុដែលមេធាវីការពារក្តីត្រូវតទល់ជាមុននោះទេ[47]។ អាស្រ័យហេតុនេះ ពាក់ព័ន្ធនឹងចម្លើយសាក្សីទាំងអស់នេះ បើភាគីនានាមានបំណង ភាគីអាចប្រើប្រាស់សវនាការលើឯកសារដែលនឹងមាន ឬបើមិនដូច្នោះទេ ភាគីនឹងត្រូវបានផ្តល់ឲ្យនូវឱកាសធ្វើការជំទាស់ទៅនឹងភ័ស្តុតាងនេះ (ផ្នែក ៤.៤)។ ទោះបីជាក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនឹងផ្តល់តម្លៃ និងទម្ងន់ជាភ័ស្តុតាងលើ

---

[46] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៨៥-៨៨។ *សូមមើលផងដែរ* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកនៃឯកសារលេខ E114, E114/1, E131/1/9, E131/6, E136 និង E158, E162 ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ("សម្រង់សេចក្តីសម្រេចផ្ទាល់មាត់") កថាខណ្ឌ ៣ (កត់សម្គាល់ឃើញថា ករណីនេះអនុវត្តតែចំពោះឯកសារទាំងឡាយដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ ប៉ុន្តែពុំអនុវត្តចំពោះឯកសារផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងឡើយ) និងសេចក្តីសម្រេចលើក្របខណ្ឌឯកសារ កថាខណ្ឌ ២០។

[47] ឯកសារទាំងនេះរួមទាំងចម្លើយសាក្សីចំនួន ១៥០ ច្បាប់ ដែលពុំទាន់បានផ្តល់ចម្លើយនៅឡើយ គិតមកត្រឹមថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២។ ចម្លើយទាំងនេះប្រហែល ៧១ គឺបានមកពីសាក្សីនានា ដែលអង្គជំនុំជម្រះគ្រោងនឹងស្តាប់ចម្លើយ (E131.1)។ ភាពអាចទុកចិត្តបានលើសាក្សីទាំងនេះអាចទំនងជាត្រូវសួរដេញដោលនៅក្នុងតុលាការនាពេលណាមួយសមស្រប ហើយមានចម្លើយមួយគឺជារបស់សាក្សីម្នាក់ដែលបានទទួលមរណភាពហើយនោះ (ឯកសារលេខ E3/35)។

កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់នេះ ប្រសិនបើមាន ឲ្យបានសមស្របតាមលក្ខណវិនិច្ឆ័យខាងលើ (ផ្នែក ៤.២)។

### *៤.៣.២. ចម្លើយសាក្សីដែលមិនត្រូវបានកោះហៅឲ្យផ្តល់ភស្តុតាងនៅពេលសវនាការ ដែលត្រូវបានធ្វើឡើងដោយអង្គភាពនានានៅក្រៅ អ.វ.ត.ក*

២៩ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងឡាយ ឬភស្តុតាងប្រមូលបានផ្សេងទៀតដែលមិនស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គការអន្តរការីផ្សេងទៀត ឬអង្គភាពផ្សេងដែលនៅក្រៅ អ.វ.ត.ក ពុំត្រូវបានសន្មតថា មានភាពអាចជឿជាក់បាននោះទេ[48]។ ទោះបីជាយ៉ាងណាក៏ដោយ ភស្តុតាងនេះអាចត្រូវបានអង្គជំនុំជម្រះស្នើឲ្យបង្ហាញជូន អនុលោមតាមវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។ ទោះបីជាក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនបានតម្រូវក៏ដោយ សូចនាករនៃភាពជឿទុកចិត្ត (ដូចជា សូចនាករនៃភាពជឿទុកចិត្តទាំងឡាយដែលបានផ្តល់ឲ្យដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកំណត់ហេតុជាច្រើន) អាចជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃ ថាតើភស្តុតាងដែលលើកឡើងបំពេញលក្ខខណ្ឌនានា ដែលមាននៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងតម្លៃជាភស្តុតាង ព្រមទាំងទម្ងន់ជាភស្តុតាងដែលមានចំពោះភស្តុតាងនោះបានដែរ ឬទេ[49]។ នៅពេលគ្មានព័ត៌មានពាក់ព័ន្ធនឹងកាលៈទេសៈនានាដែលគេបានធ្វើកំណត់ហេតុ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ដែលជាញឹកញាប់ត្រូវបានអង្គការអន្តរការីផ្សេងៗរៀបចំឡើង ក្នុងនាមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ក៏អាចត្រូវបានស្នើឲ្យបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះផងដែរ ប៉ុន្តែនៅទីបំផុត អាចត្រូវបានផ្តល់ឲ្យនូវទម្ងន់ជាភស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមាន។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គល

---

[48] សេចក្តីសម្រេចលើក្របខ័ណ្ឌឯកសារ កថាខណ្ឌ ២០ (កត់សម្គាល់ឃើញថា ការសន្មតថាមានភាពអាចជឿជាក់បាន គឺចំពោះតែកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស ដោយហេតុថា កំណត់ហេតុទាំងនេះត្រូវបានរៀបចំឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និងគោរពទៅតាមការធានាយ៉ាងជាក់លាក់លើយថាភាព និងភាពទុកចិត្តបាន) និងកថាខណ្ឌ ២៨ (ការ សន្មតថាមានភាពពាក់ព័ន្ធ និងភាពទុកចិត្តបាន រួមទាំងយថាភាព គឺអាស្រ័យទៅលើឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាន ក្រោយពីពិនិត្យមើលឡើងវិញនូវគោលនយោបាយ និងការអនុវត្តចំពោះឯកសាររបស់មជ្ឈមណ្ឌលកម្ពុជា)។

[49] *សូមមើល* សេចក្តីសន្និដ្ឋានលើវិធាន ៩២ របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងតម្រុយនៃភាពទុកចិត្តបានចំពោះឯកសារចំនួន ៩៧៨ នៅក្នុងបញ្ជី ដែលជាប់ពាក់ព័ន្ធនឹងអ្នកជំនាញ និងសាក្សី ដែលទំនងជានឹងអាចត្រូវបានកោះហៅនៅក្នុងអំឡុងពេលបីសប្តាហ៍ដំបូងនាពេលសវនាការ ឯកសារលេខ E158 ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១។

នីមួយៗដែលនៅទីបំផុតមិនត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២/០១ (កថាខណ្ឌ ៦ ខាងលើ) និងបណ្តឹងទាំងឡាយដែលមិនពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃសវនាការនៅក្នុងសំណុំរឿង ០០២/០១ អាចខកខានថែមទៀតក្នុងការបំពេញលក្ខណវិនិច្ឆ័យនៃភាពពាក់ព័ន្ធ អនុលោមតាមវិធាន ៨៧(៣)(ក) នៃវិធានផ្ទៃក្នុង។

### *៤.៣.៣. ប្រតិចារឹកនៃភស្តុតាងដែលបានពីសំណុំរឿង ០០១*

៣០ ទោះបីជាមានការឯកភាពជាមួយនឹងសហព្រះរាជអាជ្ញាថា ប្រតិចារឹកស្តីពីសវនាការបានពីសំណុំរឿង ០០១ មានសូចនាករដែលមានភាពអាចជឿជាក់បានក៏ដោយ ក៏ប្រតិចារឹកនៃភស្តុតាងដែលបានពីសវនាការនេះអាចនឹងត្រូវបានប្រើប្រាស់ដោយតិចតួចនៅក្នុងសំណុំរឿង ០០២ នៅពេលដែលភាគីនានា និងអង្គហេតុនានាដែលបានចោទឡើង មានភាពខុសគ្នា។ អង្គជំនុំជម្រះបានធ្វើការពិចារណារួចហើយអំពីកាលៈទេសៈទាំងឡាយ ដែលមិនតម្រូវឱ្យមានការចូលរួមរបស់សាក្សី និងជំនួសមកវិញ អង្គជំនុំជម្រះនឹងគ្រាន់តែទទួលយកភស្តុតាងដែលមានទម្រង់ជាប្រតិចារឹក នៅពេលដែលភស្តុតាងនោះបង្ហាញអំពីបញ្ហាក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ផ្នែក ៤.២.២)[50]។

---

[50] *សូមមើល ឧ. សេចក្តីសម្រេចលើករណី Haradinaj* កថាខណ្ឌ ១៩ (កត់សម្គាល់ឃើញថា វិធាន ៩២ *ស្ទួន* របស់តុលាការ ICTY មានគោលបំណងយកមកប្រើប្រាស់សម្រាប់បង្ហាញភស្តុតាង "ពាក់ព័ន្ធនឹងបទល្មើស" ហើយអនុញ្ញាតឱ្យទទួលយកប្រតិចារឹក និងចម្លើយទាំងនេះ ក្រោយពីបានស្តាប់សក្ខីកម្មដោយផ្ទាល់មាត់ ប្រសិនបើប្រតិចារឹក និងចម្លើយទាំងនោះបង្ហាញភស្តុតាងអំពីករណីនានាក្រៅពីអំពើ និងអាកប្បិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងផ្នែកនៃសេចក្តីសម្រេច (ដោយទទួលយកសំណើរបស់រដ្ឋអាជ្ញាត្រង់ផ្នែកខ្លះ ហើយទទួលយកប្រតិចារឹកមួយចំនួនពីសវនាការមុនៗយកមកធ្វើជាភស្តុតាង អនុលោមតាមវិធាន ៩២ *ស្ទួន* ក៏ប៉ុន្តែ តម្រូវឱ្យសាក្សីផ្សេងទៀតចូលខ្លួននៅចំពោះមុខតុលាការដើម្បីសួរតទល់ និងតម្រូវឱ្យសាក្សីដទៃទៀតចូលខ្លួនមកផ្តល់ភស្តុតាងដោយផ្ទាល់មាត់) និង *រដ្ឋអាជ្ញា ទល់នឹង Sikirica និងជនផ្សេងទៀត* សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកប្រតិចារឹក អនុលោមតាមវិធាន ៩២ *ស្ទួន* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-8-T) ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ២-៤ (អនុញ្ញាតឱ្យទទួលយកប្រតិចារឹកនៃភស្តុតាង ដែលសាក្សីបានឆ្លើយនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការផ្សេងមួយទៀត ដោយពុំទាមទារឱ្យសាក្សីមកផ្តល់សាក្សីកម្មម្តងទៀត ប្រសិនបើភស្តុតាងបង្ហាញអំពីករណីនានា ក្រៅពីសកម្មភាព និងទង្វើរបស់ជនជាប់ចោទ និងប្រសិនបើភស្តុតាងមានភាពពាក់ព័ន្ធ និងមានតម្លៃជាភស្តុតាង ព្រមទាំងប្រសិនបើការដកចេញភស្តុតាងទាំងនេះ ពុំទាមទារដោយភាពចាំបាច់ក្នុងការធានានូវការជំនុំជម្រះដោយយុត្តិធម៌។ ករណីដែលថាតើប្រតិចារឹកនេះបង្ហាញភស្តុតាងអំពីធាតុផ្សំដ៏សំខាន់នៅក្នុងរឿងក្តីរបស់រដ្ឋអាជ្ញាប្រឆាំងនឹងជនជាប់ចោទ និងករណីថាតើការសួរដេញដោលសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីផ្សេងទៀត លើកឡើងយ៉ាងសមស្របអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងក្រុមការពារក្តីនៅក្នុងកិច្ច

៣១ ជាប្រយោជន៍នៃការធានាឱ្យមានភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ក្របខ័ណ្ឌគតិយុត្តរបស់តុលាការអន្តរជាតូបនីយកម្មផ្សេងៗទៀតក៏បានអនុញ្ញាតផងដែរ ប៉ុន្តែក្រោមលក្ខខណ្ឌមួយចំនួន ឱ្យមានការប្រើប្រាស់ប្រតិចារឹកនៃភស្តុតាងរបស់បុគ្គលម្នាក់ៗ ដែលបានពីសវនាការមុនៗ នៅពេលដែលភស្តុតាងរបស់បុគ្គលនោះ នៅក្នុងសវនាការក្រោយមកទៀត នឹងមានភាពច្រំដែលទៅនឹងសក្ខីកម្មកាលពីមុនរបស់ខ្លួន ទោះបីជាវានឹងបង្ហាញភស្តុតាងពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទក៏ដោយ[51]។ ដើម្បីធានាឱ្យមានភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ហេតុដូច្នេះ យោងតាមការអនុវត្តជាក់ស្តែងនេះ ភាគីនានាអាចស្នើសុំឱ្យទទួលយកប្រតិចារឹកនៃភស្តុតាងដែលបានពីសំណុំរឿង ០០១ នៅពេលដែលសវនាការស្តាប់ការដេញដោលលើភស្តុតាងឡើងវិញរបស់បុគ្គលនោះ ទំនងជាមានភាពច្រំដែលទៅនឹងភស្តុតាងដែលត្រូវបានស្តាប់កាលពីមុន នៅពេលដែលសាក្សីរូបនោះអាចមកចូលរួមនៅក្នុងតុលាការ សម្រាប់ការសួរដេញដោលប្រសិនបើចាំបាច់ និងនៅពេលដែលសាក្សីរូបនោះទទួលស្គាល់ថា ប្រតិចារឹកដែលបានលើកឡើងឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីអ្វីដែលសាក្សីនឹងនិយាយបំភ្លឺ ប្រសិនបើគាត់ត្រូវបានគេសួរដេញដោល។

### *៤.៣.៤. ចម្លើយរបស់សាក្សីដែលបានស្លាប់ ឬសាក្សីដែលមិនអាចទាក់ទងបានទោះបីជាមានការខិតខំប្រឹងប្រែងស្វែងរកយ៉ាងសមស្របក៏ដោយ ឬសាក្សីដែលមិនអាចផ្តល់សក្ខីកម្មបាន*

៣២ ជាចុងក្រោយ វិធាន និងការអនុវត្តពាក់ព័ន្ធនានា នៅកម្រិតអន្តរជាតិ នៅក្រោមកាលៈទេសៈមួយចំនួន អនុញ្ញាតឱ្យមានការទទួលយកភស្តុតាងរបស់សាក្សីនានា ដែលបានស្លាប់ ក្រោយពីពួក

---

ដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន គឺស្ថិតក្នុងចំណោមករណីនានាដែលត្រូវយកមកពិចារណា នៅក្នុងការសម្រេចថាតើគួរតម្រូវឱ្យសាក្សីចូលខ្លួនដែរឬទេ។

[51] *សូមមើល ឧ.* វិធាន ៩២ *ស្ទួនពីរ* (ក)នៃតុលាការ ICTY (ចែងបម្រុងទុកអំពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកនៃភស្តុតាង ដែលសាក្សីបានផ្តល់ឱ្យនៅក្នុងកិច្ចដំណើរការនីតិវិធីមុនៗ ក្នុងករណីដែលសាក្សីមានវត្តមាននៅក្នុងតុលាការ ដើម្បីសួរតទល់ និងសម្រាប់ឱ្យចៅក្រមសួរ និងក្នុងករណីដែលសាក្សីបានឆ្លើយអះអាងថា ចម្លើយជាលាយលក្ខណ៍អក្សរ ឬ ប្រតិចារឹកនេះ ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីសេចក្តីប្រកាសរបស់ខ្លួន និងអ្វីដែលខ្លួនបានឆ្លើយ នៅពេលសួរសាក្សីនេះ)។ អនុលោមតាមវិធាន ៩២ *ស្ទួនពីរ* (ខ) នៃតុលាការ ICTY ភស្តុតាងបែបនេះអាចរួមបញ្ចូលទាំងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ *សូមមើល ឧ. រដ្ឋអាជ្ញា ទល់នឹង Tolimir* សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកភស្តុតាង អនុលោមតាមវិធាន ៩២ *ស្ទួនបី* អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY IT-05-88/2-PT ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣០។

គាត់បានផ្តល់ចម្លើយ ឬសាក្សីដែលមិនអាចទាក់ទងបានទោះបីជាមានការខិតខំប្រឹងប្រែងស្វែងរកយ៉ាងសមស្របក៏ដោយ ឬជាសាក្សីដែល "មិនអាចផ្តល់សក្ខីកម្មផ្ទាល់មាត់បានទេ ដោយសារតែស្ថានភាពផ្លូវកាយ ឬផ្លូវចិត្ត"[52]។ នៅចំពោះមុខតុលាការ ICTY ប្រការដែលថា ភ័ស្តុតាងដែលបានលើកឡើងគឺជាភ័ស្តុតាងពាក់ព័ន្ធទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនអាចជាឧបសគ្គក្នុងការមិនទទួលយកធ្វើជាភស្តុតាងនោះទេ ប៉ុន្តែត្រូវបានចាត់ទុកថា ជាកត្តាដែលត្រូវថ្លឹងថ្លែងអំពីទម្ងន់នៃភស្តុតាងទៅវិញ[53]។ ការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹករបស់សាក្សីដែលបានស្លាប់ ឬសាក្សីដែលរកមិនឃើញត្រូវបានអនុញ្ញាត នៅពេលដែលអង្គជំនុំជម្រះជឿជាក់ថា សាក្សីពិតជា

---

[52] *សូមមើល* វិធាន ៩២ *ស្ទួនបី* (ក) នៃតុលាការ ICTY ("អាចទទួលយកភស្តុតាងរបស់ជនម្នាក់ក្នុងទម្រង់បែបបទជាកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬ ប្រតិចារឹក ដែលក្រោយមកជននេះបានទទួលមរណភាព ឬ ដែលពុំអាចតាមរកឃើញទោះបានខំប្រឹងប្រែងយ៉ាងសមហេតុផលហើយក៏ដោយ ឬ ដែលពុំអាចផ្តល់សក្ខីកម្មដោយផ្ទាល់មាត់បាន ដោយហេតុផលនៃស្ថានភាពរាងកាយ ឬស្មារតី ដោយពុំគិតថាតើចម្លើយជាលាយលក្ខណ៍អក្សរនេះស្ថិតក្នុងទម្រង់បែបបទដូចមានចែងនៅក្នុងវិធាន ៩២ *ស្ទួន* ដែរឬអត់នោះទេ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង៖ (i) ជឿថា ជននេះពុំមានលទ្ធភាពដូចបានលើកឡើង ខាងលើមែន ហើយយល់ឃើញថា កាលៈទេសៈដែលចម្លើយនេះបានធ្វើឡើង និងកត់ត្រាទុក គឺគួរឲ្យទុកចិត្តបាន។ *សូមមើលផងដែរ* វិធាន ៩២ *ស្ទួន* (គ) ក្នុងករណីដែលអង្គជំនុំជម្រះអាចទទួលយកចម្លើយរបស់ជនម្នាក់ ដែលក្រោយមកជននេះបានទទួលមរណភាព ឬដែលពុំអាចតាមរកឃើញ ទោះបានយកចិត្តទុកដាក់យ៉ាងសមហេតុផលហើយក៏ដោយ ឬ ក្នុងកាលៈទេសៈដែលថាចម្លើយនេះបានធ្វើឡើង និងកត់ត្រាទុក បានផ្តល់នូវតម្រុយគួរឲ្យជឿជាក់អំពីភាពទុកចិត្តបាន (*សូមមើល ឧ. រដ្ឋអាជ្ញា ទល់នឹង Bagosora និងជនផ្សេងទៀត*, សេចក្តីសម្រេចលើការទទួលយកចម្លើយរបស់សាក្សីដែលបាន ទទួលមរណភាព អង្គជំនុំជម្រះសាលាដំបូងទី I នៃតុលាការ ICTR (ICTR-98-41-T) ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ១៥ ១៩ ២១។ *រដ្ឋអាជ្ញា ទល់នឹង Bagosora និងជនផ្សេងទៀត* សេចក្តីសម្រេចលើការទទួលយកចម្លើយរបស់ សាក្សី Kabiligi អនុលោមតាមវិធាន ៨៩ (គ) អង្គជំនុំជម្រះសាលាដំបូងទី I នៃតុលាការ ICTR (ICTR-98-41-T) ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ៦-៨))។

[53] *សូមមើល* វិធាន ៩២ ស្ទួនបី (ខ) នៃតុលាការ ICTY ("ប្រសិនបើភ័ស្តុតាងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមែននោះ ករណីនេះអាចជាកត្តាមួយដែលមិនអាចឲ្យទទួលយកភ័ស្តុតាងបែបនេះ ឬ ផ្នែកណាមួយនៃភ័ស្តុតាងនេះបានឡើយ") និងសេចក្តីសម្រេចលើករណី *Tolimir* កថាខណ្ឌ ៣០ ("បទប្បញ្ញត្តិនេះ [វិធាន ៩២ *ស្ទួនបី* (ខ)] មានលក្ខណៈបត់បែនដើម្បីធានានូវការជំនុំជម្រះដោយយុត្តិធម៌ និងភាពទុកចិត្តបាននៃភ័ស្តុតាង។ បទប្បញ្ញត្តិនេះ បង្គាប់ឲ្យតាមដានដោយប្រុងប្រយ័ត្នលើភ័ស្តុតាងដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ និងចែងអំពីការទទួលយកចម្លើយរបស់ជនដែលបានទទួលមរណភាព ដែលក្នុងចម្លើយនេះបានផ្តល់ជាភ័ស្តុតាង")។

មិនត្រូវបានរកឃើញ និងថា ភ័ស្តុតាងដែលបានស្នើសុំឱ្យទទួលយក មានភាពអាចជឿជាក់បាន[54] និងនៅពេលដែលអង្គជំនុំជម្រះពិចារណាឃើញថា តម្លៃនៃភ័ស្តុតាង មិនមានទំហំធំធេងជាសារវន្ត ដែលធ្វើឱ្យការធានានាការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ មិនអាចប្រព្រឹត្តទៅបាននោះ[55]។

៣៣ នៅពេលដែលផលប្រយោជន៍នៃភាពយុត្តិធម៌តម្រូវ វិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY អនុញ្ញាតឱ្យមានការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗផងដែរ ទោះបីជាភ័ស្តុតាងនោះពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទក៏ដោយ ដរាបណាការខកខានរបស់គាត់មិនបានចូលរួមនៅក្នុងសវនាការ ឬផ្តល់ភ័ស្តុតាង បណ្តាលមកពីការគំរាមកំហែងការបំភិតបំភ័យ ឬទម្រង់ផ្សេងៗនៃការជ្រៀតជ្រែកដោយមិនត្រឹមត្រូវ[56]។

---

[54] *សូមមើល* សេចក្តីសម្រេចលើករណី *Popović* កថាខណ្ឌ ៣១ និង *រដ្ឋអាជ្ញា ទល់នឹង Tolimir* សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកភ័ស្តុតាង អនុលោមតាមវិធាន ៩២ ស្ទួនបី អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY (IT-05-88/2-PT) ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចលើករណី *Tolimir*") កថាខណ្ឌ ២៩ (បង្ហាញថាកត្តាដូចខាងក្រោម មានភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃលើភាពទុកចិត្តបាននៃភស្តុតាង ដូចបានស្នើសុំអនុលោមតាមវិធាន ៩២ *ស្ទួនបី* (i) កាលៈទេសៈ ដែលចម្លើយនេះធ្វើឡើង និងកត់ត្រាទុក រួមទាំងករណីដែលថាតើចម្លើយទាំងនេះបានផ្តល់ជូនក្រោយពីបានធ្វើសម្បថដែរ ឬទេ ចម្លើយនេះបានចុះហត្ថលេខាដោយសាក្សី អមជាមួយនឹងការទទួលស្គាល់ថា ចម្លើយនេះឆ្លើយការពិតតាមការចងចាំរបស់សាក្សីដែរឬទេ (iii) ចម្លើយនេះបានធ្វើឡើងដោយមានការជួយជ្រោមជ្រែងពីអ្នកបកប្រែដែលមានគុណវុឌ្ឍិត្រឹមត្រូវដែរ ឬទេ (ii) ចម្លើយនេះត្រូវបានដាក់ឱ្យសួរតទល់ដែ រឬទេ ហើយពាក់ព័ន្ធនឹងព្រឹត្តការណ៍ដែលបង្ហាញនូវភ័ស្តុតាងផ្សេងដែរ ឬទេ និង (iv) កត្តាផ្សេងទៀត ដូចជា អវត្តមាននៃភាពពុំស៊ីសង្វាក់គ្នាយ៉ាងជាក់ស្តែង និងច្បាស់ក្រឡែតនៅក្នុងចម្លើយទាំងនេះ។ *សូមមើលបន្ថែម* សេចក្តីសម្រេចលើករណី *Popović* កថាខណ្ឌ ៣០ និង សេចក្តីសម្រេចលើករណី *Tolimir* កថាខណ្ឌ ២៧-២៨ (ដែលសំដៅលើភាពចាំបាច់ក្នុងការបំពេញទៅតាមលក្ខខណ្ឌទូទៅ នៃការទទួលយក នៅក្នុងវិធាន ៨៩ ស្តីអំពីភាពពាក់ព័ន្ធ តម្លៃជាភ័ស្តុតាង និងអនុលោមភាពជាមួយនឹងលក្ខខណ្ឌនៃការជំនុំជម្រះដោយយុត្តិធម៌)។

[55] *រដ្ឋអាជ្ញា ទល់នឹង Karadžić* សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកភ័ស្តុតាងរបស់ KDZ172 (Milan Babić) អនុលោមតាមវិធាន ៩២ *ស្ទួនបី* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣ និង *រដ្ឋអាជ្ញា ទល់នឹង Karadžić* សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកភ័ស្តុតាងរបស់ Milenko Lazić អនុលោមតាមវិធាន ៩២ *ស្ទួនបី* និងស្នើសុំការអនុញ្ញាតបន្ថែមវត្ថុតាងអនុលោមតាមបញ្ជីវត្ថុតាងនៃវិធាន ៦៥ *ស្ទួនពីរ* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY IT-95-5/18-T ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ២០-២៣ (បដិសេធចម្លើយ ដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលបានផ្តល់ជូនសាក្សីដែលបានទទួលមរណភាព ដោយហេតុថា ចម្លើយបែបនេះពុំត្រូវបានយកមកសួរដេញដោល និង "ដោយហេតុថា ភាពចាំបាច់នៃការធានានូវការជំនុំជម្រះដោយយុត្តិធម៌ មានតម្លៃជាងតម្លៃនៃភ័ស្តុតាងរបស់ភ័ស្តុតាងបែបនេះ")។

[56] *សូមមើល* វិធាន ៩២ *ស្ទួនបួន* (ក) នៃតុលាការ ICTY ("អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងរបស់ជនណាម្នាក់ដែលមានទម្រង់ជាចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកនៃភ័ស្តុតាងដែលបុគ្គលនេះបានផ្តល់ជូន នៅក្នុងកិច្ចដំណើរការ

00818205



## ៤.៤ បែបបទនីតិវិធីដើម្បីស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនៅចំពោះមុខអង្គជំនុំជម្រះ យោងតាមសេចក្តីសម្រេចនេះ

៣៤ ប្រភេទសម្ភារៈមួយចំនួនដែលបានលើកឡើងនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា ក៏ដូចជាប្រភេទសម្ភារៈដែលបានស្នើឡើងដោយសហមេធាវីនាំមុខ រួមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនធំ និងភស្តុតាងផ្សេងទៀត (ដូចជា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងទាំងឡាយ) ជាញឹកញាប់មិនមានការបញ្ជាក់ពីគោលបំណងដែលគេបានស្នើសុំឱ្យទទួលយកសម្ភារៈឱ្យបានច្បាស់លាស់នោះទេ។ ជាប្រយោជន៍នៃការគ្រប់គ្រងសវនាការប្រកបដោយប្រសិទ្ធភាព អង្គជំនុំជម្រះតម្រូវឱ្យភាគីនានាកំណត់អំពីគោលបំណងសម្រាប់ការដាក់ភស្តុតាង ដើម្បីជួយដល់ការវាយតម្លៃលើភាពអាចទទួលយកបាននៃភស្តុតាង និងតម្លៃជាភស្តុតាងនៃសម្ភារៈដែលបានដាក់ ប្រសិនបើត្រូវបានរកឃើញថា អាចទទួលយកបាន យោងតាមលក្ខខណ្ឌខាងលើ (ផ្នែក ៤.២ និង ៤.៣)។ ទោះបីជាអង្គជំនុំជម្រះបានបង្ហាញថា សម្ភារៈនេះភាគច្រើនទំនងជានឹងត្រូវទទួលបានទម្ងន់ជាភស្តុតាងតិចតួចប៉ុណ្ណោះក៏ដោយ ក៏ផលប៉ះពាល់នៃការគ្រប់គ្រងសវនាការនៃសំណើទាំងអស់នេះ (ដោយគិតអំពីសេចក្តីត្រូវការបកប្រែឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ក៏ដូចជាសក្តានុពលដើម្បីផ្តល់ពេលវេលាច្រើន សម្រាប់ស្តាប់សវនាការសួរដេញដោលអំពីការជំទាស់ទៅនឹងសម្ភារៈនេះ) នៅតែសំខាន់ជាពិសេស ប្រសិនបើភាគីនានានៅតែរក្សាសំណើយ៉ាងទូលំទូលាយ សុំដាក់

---

នីតិវិធីចំពោះមុខសាលាក្តី ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា (i) ជននេះពុំបានចូលរួមក្នុងនាមជាសាក្សី ឬ បានចូលរួម តែពុំបានផ្តល់ភស្តុតាងទាល់តែសោះ សូម្បីចំណុចសំខាន់ៗក៏ដោយ (ii) ជននេះពុំបានចូលរួម ឬ ផ្តល់ភស្តុតាង ដោយសារតែការជ្រៀតជ្រែកដោយពុំត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត រួមមានដូចជា ការគម្រាមកំហែង ការបំភិតបំភ័យ ការបង្ករបួសស្នាម ការសូកប៉ាន់ ឬ ការបង្ខិតបង្ខំ (iii) ក្នុងករណីដែល[...]ការខិតខំប្រឹងប្រែងបានធ្វើឡើងយ៉ាងសមហេតុផល [...] ដើម្បីធ្វើយ៉ាងណាឱ្យជននេះចូលខ្លួនក្នុងនាមជាសាក្សី ឬ ប្រសិនបើជននេះបានចូលខ្លួនហើយនោះ ធ្វើឱ្យសាក្សីឆ្លើយនូវអង្គហេតុជាក់លាក់ទាំងអស់ដែលសាក្សីបានដឹង និង (iv) ផលប្រយោជន៍នៃយុត្តិធម៌ បានផ្តល់ជូនរួចហើយដោយការបំពេញកិច្ចទាំងនេះ។ កត្តានានាដែលពាក់ព័ន្ធនឹងការកំណត់នូវផលប្រយោជន៍នៃយុត្តិធម៌ អនុលោមតាមអនុវិធាននេះរួមមាន៖ (ក) ភាពទុកចិត្តបាននៃចម្លើយ ឬ ប្រតិចារឹក ក្រោយពីបានពិនិត្យលើកាលៈទេសៈដែលចម្លើយនេះបានធ្វើឡើង និងកត់ត្រាទុក (ខ) តួនាទីជាក់ស្តែងនៃភាគី ឬ បុគ្គលតំណាងឱ្យភាគីនៃកិច្ចដំណើរការនីតិវិធី នៅក្នុងជ្រៀតជ្រែកដោយពុំសមស្រប និង (គ) ចម្លើយ ឬ ប្រតិចារឹកនេះបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

កំណត់ហេតុលាយលក្ខណ៍អក្សរ ឬភ័ស្តុតាងផ្សេងទៀតដ៏ច្រើនសន្ធឹកសន្ធាប់ នៅចំពោះមុខអង្គជំនុំជម្រះ[57]។

៣៥ យោងលើការពិចារណាទាំងអស់នេះ ភាគីនានាដែលស្នើសុំដាក់ភ័ស្តុតាងដែលត្រូវបានវាយតម្លៃតាមរយៈសេចក្តីសម្រេចនេះ ត្រូវបានណែនាំឱ្យៈ

ក) ពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ ដែលមាននៅលើបញ្ជីពាក់ព័ន្ធរបស់ខ្លួន ដើម្បីឱ្យស្របជាមួយនឹងលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបាន ដែលបានកំណត់នៅក្នុងផ្នែក ៤.២ និង ៤.៣ នៃសេចក្តីសម្រេចនេះ។

ខ) បញ្ជាក់គោលបំណងនៃភ័ស្តុតាងរបស់ឯកសារនីមួយៗឱ្យបានច្បាស់លាស់ ឬប្រភេទនៃភ័ស្តុតាងនីមួយៗដែលត្រូវបានស្នើសុំ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំ-ជម្រះ ជាពិសេស នៅពេលដែលមូលហេតុជាក់លាក់នានាត្រូវបានលើកឡើងសម្រាប់ជាយុត្តិកម្មលើការទទួលយកកំណត់ហេតុទាំងឡាយ ដែលបង្ហាញភ័ស្តុតាងពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដោយមិនចាំបាច់ស្តាប់សក្ខីកម្មសាក្សីក្នុងពេលសវនាការ។

គ) នៅពេលដែលភ័ស្តុតាងនេះមានចំនួនច្រើន ឬ ជាពិសេស មានភាពច្រំដែល ភាគីត្រូវពិចារណាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ តែភ័ស្តុតាងមួយសម្រាប់ជាគំរូ ដែលតំណាងឱ្យប្រភេទនៃភ័ស្តុតាងនីមួយៗ (ជាជាងការដាក់រាល់ឯកសារ ឬកំណត់ហេតុទាំងអស់នៃប្រភេទភ័ស្តុតាងនីមួយៗ)។

ឃ) ផ្តល់នូវការបញ្ជាក់ច្បាស់លាស់ខាងលើ ត្រឹមថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ដើម្បីឱ្យអង្គជំនុំជម្រះអាចកំណត់ពេលសវនាការ ឬក៏អនុញ្ញាតឱ្យដាក់ការជំទាស់អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង បានឆាប់រហ័ស ប្រសិនបើចាំបាច់។

---

[57] ឧទាហរណ៍ គិតត្រឹមខែ មិថុនា ឆ្នាំ ២០១២ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាចំនួន ៩៣៥ ដែលសហមេធាវីនាំមុខបានស្នើសុំ (រួមមានប្រហែលជា ៩.០០០ ទំព័រ) ពុំទាន់បានបកប្រែនៅឡើយ។ គិតត្រឹមកាលបរិច្ឆេទដដែលបណ្តឹងប្រហែលជា ២.០០០ បណ្តឹង ដែលសហព្រះរាជអាជ្ញាបានស្នើសុំ ក៏ពុំទាន់បានបកប្រែនៅឡើយដែរ។

៣៦ នៅពេលណាដែលភ័ស្តុតាងដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ តាមសេចក្តីសម្រេចនេះ ត្រូវបានកត់សម្គាល់ដោយភាគីនានារួចហើយ ស្របតាមការណែនាំខាងលើ អង្គជំនុំជម្រះនឹងកំណត់ពេលសវនាការនាពេលវេលាសមស្រប ឬក៏ផ្តល់ឱកាសឱ្យភាគីដាក់ការជំទាស់ដែលពាក់ព័ន្ធទៅនឹងភ័ស្តុតាងដែលបានស្នើឡើង អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[58]។

**ដោយសំអាងលើហេតុផលដូចខាងលើ អង្គជំនុំជម្រះសាលាដំបូង:**

**យល់ឃើញ** ថាភ័ស្តុតាងដែលស្ថិតក្នុងទម្រង់នៃកំណត់ហេតុលាយលក្ខណ៍អក្សរ ឬប្រតិចារឹក អាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន ដរាបណា ភ័ស្តុតាងនោះបំពេញនូវលក្ខខណ្ឌ ដែលមាននៅក្នុងផ្នែក ៤.២ និង ៤.៣ នៃសេចក្តីសម្រេចនេះ។

**បង្គាប់** សហព្រះរាជអាជ្ញា និងភាគីនានាផ្សេងទៀតដែលស្នើសុំដាក់ភ័ស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះដោយឈរលើលក្ខណវិនិច្ឆ័យនេះ ឱ្យកំណត់ភ័ស្តុតាងដែលបានស្នើឡើង ដោយបញ្ជាក់ឱ្យបានច្បាស់លាស់យោងតាមបែបបទទាំងឡាយ ដែលបានកំណត់នៅក្នុងផ្នែក ៤.៤ នៃសេចក្តីសម្រេចនេះ។

**ជូនដំណឹង** ដល់ភាគីនានាថា អង្គជំនុំជម្រះនឹងផ្តល់ឱកាសឱ្យភាគីដាក់ការជំទាស់ទៅនឹងភ័ស្តុតាងដែលបានស្នើឡើង ដូចដែលបានកំណត់នៅក្នុងផ្នែក ៤.២ និង ៤.៣ និងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងតាមពេលសមស្រប។

**ប្រកាស** ថាលក្ខណវិនិច្ឆ័យដែលបានកំណត់នៅក្នុងផ្នែក ៤.២ និង ៤.៣ នៃសេចក្តីសម្រេចនេះ នឹងត្រូវយកទៅពិចារណាថែមទៀតដោយអង្គជំនុំជម្រះ នៅពេលដែលអង្គជំនុំជម្រះវាយតម្លៃអំពីតម្លៃ និងទម្ងន់នៃភ័ស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្រោយការចេញសេចក្តីសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**

[58] *សូមមើល ឧ.* ឯកសារលេខ E172/5 (ពន្យារការពិភាក្សាអំពីឯកសារទាំងឡាយដែលមាននៅក្នុងឯកសារឧបសម្ព័ន្ធ A12 និង A13 របស់សហព្រះរាជអាជ្ញា (បណ្តឹង និងចម្លើយសាក្សី) រួមទាំងឯកសារភ័ស្តុតាងភាគច្រើន ត្រូវបានស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលកំពុងរង់ចាំការចេញសេចក្តីសម្រេច)។